-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៩០២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សំរេច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយថ្នាក់ការងារ** ជូនមន្ត្រី ចំនួន ១០រូប ដែលមានស្នាដៃល្អ ក្នុងការសហការអនុវត្តគំរោងកម្មវិធី **PRASAC II** នៅកម្ពុជា ជាមួយអ្នកជំនាញការ សហគមន៍អឺរ៉ុប ដូចមានរាយនាមខាងក្រោម :-

| | | |
|---|---|---|
| ១-លោក | **សំ សារី** | អ្នកសំរបសំរួល ផ្នែកធារាសាស្ត្រ |
| ២-លោក | **ឡុង លុច** | ជំនួយការប្រធានរដ្ឋបាល |
| ៣-លោក | **ហៀង សុវណ្ណារ៉ា** | អ្នកសំរបសំរួលផ្នែក **MIS / M&E / GIS** |
| ៤-លោក | **ជា ឆាន** | គណនេយ្យករ |
| ៥-លោកស្រី | **នាន លីហួ** | អ្នកសំរបសំរួលផ្នែកអភិវឌ្ឍន៍សហគមន៍ |
| ៦-លោកស្រី | **ហ៊ិត ចរិយា** | អ្នកសំរបសំរួលផ្នែកប្រព័ន្ធទឹកស្អាត |
| ៧-កញ្ញា | **ហ៊ុយ ទូនី** | បេឡាការិនី |
| ៨-កញ្ញា | **រស់ បុប្ផា** | លេខាធិការិនី របស់ **TA Co-Director** |
| ៩-កញ្ញា | **ម៉េង ធារី** | លេខាធិការិនី របស់ **National Co-Director** |
| ១០-កញ្ញា | **ឡេង លីដា** | ជំនួយការលេខាធិការិនី |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

148-149

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩០៣ អនក្រ-ទស

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០៣គ្រឿង ជូនសប្បុរសជន ចំនួន ០៣រូប ដែលបានជួយកសាងអគារសិក្សា និង សមិទ្ធផលផ្សេងៗទៀត នៅក្នុងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោម :-

១-***ប្រធានសមាគម*** *SCHOOL AID JAPAN* ជួយកសាងអគារសិក្សា ០១ខ្នង មាន០៥ បន្ទប់ និងសមិទ្ធផលមួយចំនួនទៀត នៅសាលាបឋមសិក្សា រលាំងនាគ ភូមិ ត្រពាំងទន្លាប់ ឃុំស្វាយជុក អស់ថវិកា ចំនួន ៣២.០០០ ដុល្លារ ។

២-***ប្រធានសមាគម*** *SCHOOL AID JAPAN* ជួយកសាងអគារសិក្សា ០១ខ្នង មាន ០៥បន្ទប់ និង សមិទ្ធផលមួយចំនួនទៀត នៅសាលាបឋមសិក្សាក្រាំងស្រម៉ ភូមិក្រាំងស្រម៉ ឃុំស្វាយជុក អស់ថវិកា ចំនួន ៣២.០០០ ដុល្លារ ។

៣-***សមាគម*** *YAMAGATA PREFECTURAL COUNCIL OF AGRICULTURAL COOPERATIVE WOMEN'S ASSOCIATION* ជួយកសាងអគារសិក្សា ០១ ខ្នង មាន ០៥ បន្ទប់ និង សមិទ្ធផលមួយចំនួនទៀត តាមរយៈអង្គការ S.V.A នៅសាលាបឋមសិក្សាច្រកស្តេច ឃុំពាម អស់ថវិកា ចំនួន ២៤.៨៥២,៣៣ ដុល្លារ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវ អនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៩០៤ អនក្រ-បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## សំ រេ ច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០២រូប ដែលបានបរិច្ចាគធនធានជួយកសាងសួនច្បារ និង ដាំដើមឈើ ក្នុងទីរួមខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

១-លោក **John Nalson** អគ្គនាយកក្រុមហ៊ុន **BAT** ថវិកា ចំនួន ១១.០០០ ដុល្លារ

២-លោកបណ្ឌិត **ជួន ឧុឡ្សី** នាយកក្រុមហ៊ុន **BAT** ប្រចាំខេត្តកំពង់ចាម ថវិកា ចំនួន ១០.៥០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវ អនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ..៩០៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

**ស ម្រេ ច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ចំនួន ០៧ គ្រឿង ជូនមន្ត្រីរាជការចូលនិវត្តន៍ នៃក្រសួងធម្មការ និង សាសនា ចំនួន ០៧ រូប ដែលកន្លងមកបានខិតខំយ៉ាងសកម្មក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ ហើយក្រោយពីបានចូលនិវត្តន៍ នៅបានជួយបំរើក្នុងវិស័យព្រះពុទ្ធសាសនា អស់ពីកំលាំងកាយចិត្ត តាមជំនាញរៀងៗខ្លួន ជូនក្រសួងធម្មការ និង សាសនា ដូចមានរាយនាមខាងក្រោមនេះ :-

១-លោក **យ៉េន ខុន** អតីត ប្រធាននាយកដ្ឋាន

២-លោក **ឆោ ឆុន** អតីត អនុប្រធាននាយកដ្ឋាន

៣-លោក **ម៉ី យ៉ាំ** អតីត អនុប្រធាននាយកដ្ឋាន

៤-លោក **ចាន្ទ ចំនួ** អតីត អនុប្រធាននាយកដ្ឋាន

៥-លោក **សុខ ពិន** អតីត អនុប្រធាននាយកដ្ឋាន

៦-លោក **អ៊ុ យ៉ឿង** អតីត អនុប្រធាននាយកដ្ឋាន

៧-លោក **ស៊ឹម អ៊ុម** អតីត អនុប្រធាននាយកដ្ឋាន

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ៗ៖ ៣

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

121 -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៩០៦ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ស៊ុត តារា** ប្រធាននាយកដ្ឋាន កាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកកសាងសមិទ្ធផល សាធារណៈផ្សេងៗ លើវិស័យអប់រំ ព្រះពុទ្ធសាសនា គមនាគមន៍ និង សង្គមកិច្ច នៅខេត្តកណ្តាល ខេត្តតាកែវ ក្រុងព្រះសីហនុ ខេត្តក្រចេះ និង ខេត្តកំពង់ធំ ចំណាយអស់ថវិកា សរុបចំនួន ១៧៣.៥០០ ដុល្លារ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៩៥០ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**ស ំ រ េ ច**

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម **ផាត់ ប៊ុន** ទីប្រឹក្សាផ្ទាល់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកកសាងសមិទ្ធផល សាធារណៈផ្សេងៗ លើវិស័យអប់រំ ព្រះពុទ្ធសាសនា គមនាគមន៍ និង សង្គមកិច្ច នៅខេត្តកណ្តាល ចំណាយអស់ថវិកាសរុបចំនួន ១០៥.៥៩៩ ដុល្លារ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦៤ សសរ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីចុះត្រួតពិនិត្យ និងសិក្សាពីបញ្ហាវិវាទដីធ្លី នៅឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីចុះត្រួតពិនិត្យ និងសិក្សាពីបញ្ហាវិវាទដីធ្លី នៅឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- ឯកឧត្តម **សេង លឹមនៅ** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ជាប្រធាន |
| ២- ឯកឧត្តម **ឡាយ សុខា** | អភិបាលខេត្តតាកែវ | ជាសមាជិក |
| ៣-ឯកឧត្តមឧត្តមសេនីយ៍ឯក **ជា តារា** | តំណាងអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ | ជាសមាជិក |
| ៤- ឯកឧត្តម **អ៊ុក សុខុន** | អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ | ជាសមាជិក |

៥- ឯកឧត្តមឧត្តមសេនីយ៍ឯក **កែវ សាមួន** មេបញ្ជាការយោធភូមិភាគទី៣ ជាសមាជិក

៦- ឯកឧត្តម **ហូ វិចិត្រ** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

៧- ឯកឧត្តម **ហង្ស សារឿន** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

៨- លោក **ឌី សុគន្ធ** ប្រធានរដ្ឋបាលព្រៃឈើ ជាសមាជិក

៩- លោកអភិបាលស្រុកទ្រាំង ខេត្តតាកែវ ជាសមាជិក

**ប្រការ ២ :** គណៈកម្មការអន្តរក្រសួងនេះ មានភារកិច្ចដូចតទៅ ÷

- ចុះត្រួតពិនិត្យ និងសិក្សាដល់មូលដ្ឋានដែលមានវិវាទ នៅទីតាំងផ្ទៃដីដាំកូនឈើរបស់ ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ជាមួយដីរបស់ប្រជាពលរដ្ឋចំនួន ៤១៤គ្រួសារ ក្នុងឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ ហើយដែលមានយោធភូមិភាគទី៣ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទជាអ្នកអនុវត្តការដាំកូនឈើ
- ធ្វើរបាយការណ៍ វាយតំលៃ សន្និដ្ឋាន និងលើកសំណូមពរ អំពីលទ្ធផល នៃការចុះត្រួតពិនិត្យ និងសិក្សា តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីសុំយោបល់សំរេចពីប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ ៣ :** សមាជិកក្រុមការងារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ មេបញ្ជាការយោធភូមិភាគទី៣ អភិបាលខេត្តតាកែវ និងសាមីជនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៥ ...សសរ...

## សេចក្តីសំរេច
## ស្តីពីការប្រគល់ភារកិច្ចជូនអាណាប័កតាមការប្រទានសិទ្ធិនៅទីស្តីការគណៈរដ្ឋមន្ត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣

-បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០២ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣

-តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

ប្រការ១ : ត្រូវបានប្រគល់ភារកិច្ច ជូនឯកឧត្តម **ឡោក់ សុខុន** ជាអាណាប័កតាមការប្រទានសិទ្ធិ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជំនួសឯកឧត្តម **ស៊ុំ ម៉ាន់ត** ដែលត្រូវទៅព្យាបាលសុខភាពរយៈពេលវែង នៅប្រទេសបារាំង ។

ប្រការ២: ភារកិច្ចជាក់ស្តែងរបស់អាណាប័កតាមការប្រទានសិទ្ធិ ត្រូវកំណត់ដោយឡែក ដោយសេចក្តីសំរេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាអាណាប័កដើមខ្សែ ។

ប្រការ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រុមប្រឹក្សាអាជ្ញាធរជាតិ គ្រប់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ ឯកឧត្តម **ឡោក់ សុខុន** ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ ...... ឆ្នាំ ២០០៣

ហ៊ុន សែន

**ចំលងជូន**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចប្រការ (៣)
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៦៧០ ស.សរ**

# សេចក្ដីសំរេច

## ស្ដីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំ រេ ច**

**ប្រការ ១** : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្ដម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្ដីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្ដេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលកម្ពុជា- ឡាវ- មីយ៉ាន់ម៉ា និងថៃ ស្ដីពីយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ចាប់ពីថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៣ នៅបាហ្កាន សហភាពមីយ៉ាន់ម៉ារហូតដល់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត- ក្រុង និងឯកឧត្ដម ស ខេង ត្រូវអនុវត្តសេចក្ដីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៣*

**ហ៊ុន សែន**

*កន្លែងទទួល* :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២*
- *ឯកសារ- កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ : ១៥៤៥ ប្រក

# ប្រកាស
## ស្តីពី
## នីតិវិធី នៃការផ្តល់ប័ណ្ណឆ្លងដែន នៅតាមច្រកទ្វារព្រំដែនកម្ពុជា-ថៃ

***សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៥/នស/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ នស/រកត/ ០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្របក ចុះថ្ងៃ០៩ ខែកក្កដា ឆ្នាំ២០០២ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្របក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៣ ស្តីពីការប្រើប្រាស់ប័ណ្ណឆ្លងដែននៅច្រកទ្វារព្រំដែនកម្ពុជា-ថៃ
- តាមសំណើរបស់អគ្គស្នងការនគរបាលជាតិ ។

## សម្រេច

**ប្រការ១** ៖-ត្រូវបានកំណត់នីតិវិធីនៃការផ្តល់ប័ណ្ណឆ្លងដែន ដែលបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៣ ជូនប្រជាពលរដ្ឋខ្មែរ ដែលរស់នៅតាមខេត្ត ក្រុងជាប់ព្រំដែនកម្ពុជា-ថៃ ។

-ប័ណ្ណឆ្លងដែនត្រូវបានផលិតគ្រប់គ្រង និងបែងចែកទៅតាមខេត្ត ក្រុងជាប់ព្រំដែនកម្ពុជា-ថៃ ដោយក្រសួងមហាផ្ទៃ ។

-ជនណាផលិត ក្លែងបន្លំប័ណ្ណឆ្លងដែននឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**ប្រការ២ :** ប័ណ្ណឆ្លងដែនដែលត្រូវបានអនុញ្ញាតអោយប្រើប្រាស់នៅតាមច្រកទ្វារព្រំដែនកម្ពុជា-ថៃ មាន ០២ ប្រភេទ គឺ :

-ប័ណ្ណឆ្លងដែនពណ៌ខៀវ ចេញដោយអភិបាលខេត្ត ក្រុង ជាប់ព្រំដែន និង

-ប័ណ្ណឆ្លងដែនពណ៌លឿង ចេញដោយនាយប៉ុស្តិ៍នគរបាលអន្តោប្រវេសន្ត ឬនាយប៉ុស្តិ៍នគរបាលការពារព្រំដែនគោក ប្រចាំនៅច្រកទ្វារព្រំដែន ។

**ប្រការ៣ :** ប្រជាពលរដ្ឋដែលរស់នៅក្នុងស្រុក ខណ្ឌជាប់ព្រំដែនកម្ពុជា-ថៃ អាចដាក់ពាក្យសុំប័ណ្ណឆ្លងដែននៅសាលាខេត្ត ក្រុង ក៏បាន ឬ នៅប៉ុស្តិ៍នគរបាលអន្តោប្រវេសន្ត ឬ នៅប៉ុស្តិ៍នគរបាលការពារព្រំដែនគោកប្រចាំនៅច្រកទ្វារព្រំដែនក៏បាន ។

ដោយឡែកចំពោះប្រជាពលរដ្ឋដែលរស់នៅក្នុងស្រុក ខ័ណ្ឌ មិនជាប់ព្រំដែន តែជាស្រុករបស់ខេត្ត ក្រុងជាប់ព្រំដែន ត្រូវដាក់ពាក្យសុំប័ណ្ណឆ្លងដែននៅសាលាខេត្ត ក្រុង ។

**ប្រការ៤ :** -ក្នុងជំហានដំបូងនេះ ប័ណ្ណឆ្លងដែនត្រូវបានអនុញ្ញាតអោយប្រើប្រាស់សំរាប់តែប្រជាពលរដ្ឋដែលកំពង់ស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងខេត្តបន្ទាយមានជ័យមួយប៉ុណ្ណោះសិន ។

-ខេត្ត ក្រុងជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃដទៃទៀត ពុំទាន់ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ទេ ហើយអភិបាលខេត្ត ក្រុង ទាំងនេះ ត្រូវពិនិត្យតាមដានវាយតំលៃសភាពការណ៍សន្តិសុខសណ្តាប់ ធ្នាប់ជាក់ស្តែង នៅតាមតំបន់ព្រំដែនក្នុងខេត្ត ក្រុងរបស់ខ្លួន ។ ក្នុងករណីពិនិត្យឃើញថាច្រកទ្វារព្រំដែនណាមានលក្ខណៈសម្បត្តិសមស្រប អាចបើកដំណើការបាន អភិបាលខេត្ត ក្រុង ត្រូវធ្វើពាក្យស្នើសុំការអនុញ្ញាតប្រើប្រាស់ប័ណ្ណឆ្លងដែន សំរាប់ច្រកទ្វារព្រំដែននោះ មកក្រសួងមហាផ្ទៃដើម្បីពិនិត្យ និងសំរេច ។

**ប្រការ៥ :** ពាក្យសុំប័ណ្ណឆ្លងដែនត្រូវបំពេញបែបបទដូចតទៅ :

១-បំពេញពាក្យសុំប័ណ្ណឆ្លងដែន ចំនួន ០១ច្បាប់

២-ផ្តល់រូបថត ៤ x ៦ "ថតចំពីមុខគ្មានពាក់មួក ឬវ៉ែនតាពណ៌" ចំនួន ០២សន្លឹក

៣-ផ្តល់ច្បាប់ថតចំលងអត្តសញ្ញាណប័ណ្ណរបស់ខ្លួនចំនួន ០១ ច្បាប់ ឬច្បាប់ចំលងសៀវភៅស្នាក់-នៅ ឬសៀវភៅគ្រួសារចំនួន០១ ច្បាប់ ឬ លិខិតបញ្ជាក់ទីលំនៅ ចេញដោយមេឃុំ ឬ ចៅសង្កាត់ចំនួន០១ ច្បាប់

៤-បិទតែមប្រើដែលមានតម្លៃ ១.០០០៛០០ រៀល នៅលើពាក្យសុំប័ណ្ណឆ្លងដែន

៥-បង់ថ្លៃប័ណ្ណឆ្លងដែន ចំនួន ២០.០០០ រៀល

៦-កុមារអាយុក្រោម ១២ ឆ្នាំ អាចបំពេញពាក្យសុំជាមួយឪពុក ម្តាយ ឬអាណាព្យាបាលបាន

៧_ដោយឡែកចំពោះអនីតិជន ត្រូវមានលិខិតបញ្ជាក់យល់ព្រមពីឪពុក ម្តាយ ឬអាណាព្យាបាល ។

**ប្រការ៦** : សមត្ថកិច្ចដែលមានភារកិច្ចចេញប័ណ្ណឆ្លងដែន ត្រូវចេញបង្កាន់ដៃទទួលពាក្យសុំ និងចេញបង្កាន់ដៃទទួលប្រាក់តម្លៃប័ណ្ណឆ្លងដែន ហើយត្រូវចេញប័ណ្ណឆ្លងដែនជូនប្រជាពលរដ្ឋ ក្នុងរយៈពេល០២ថ្ងៃយ៉ាងយូរ ចាប់ពីថ្ងៃទទួលពាក្យសុំ ។

**ប្រការ៧** : ប័ណ្ណឆ្លងដែនទាំង០២ប្រភេទ មានសុពលភាព ០២ឆ្នាំ ហើយអាចពន្យាពេលប្រើប្រាស់បាន ០២ឆ្នាំទៀត ។ ផុតរយៈពេលពន្យានេះ មិនអាចប្រើប្រាស់បានទៀតទេ គឺត្រូវសុំធ្វើប័ណ្ណឆ្លងដែនថ្មី ។

**ប្រការ៨** : ពាក្យសុំពន្យាពេលត្រូវធ្វើនៅកន្លែងដើមដែលប័ណ្ណនោះត្រូវបានចេញអោយ ហើយត្រូវបំពេញបែបបទ ដូចតទៅ :

១_បំពេញពាក្យសុំពន្យាពេលប័ណ្ណឆ្លងដែន ចំនួន ០១ច្បាប់

២_ផ្តល់រូបថត ៤ x ៦ "ថតចំពីមុខគ្មានពាក់មួកឬវ៉ែនតាពណ៌" ចំនួន ០១សន្លឹក

៣_បិទតែមប្រ៊ីដែលមានតម្លៃស្មើនឹង៥០០៖០០ រៀល នៅលើពាក្យសុំពន្យាពេលប័ណ្ណឆ្លងដែន ។

**ប្រការ៩** : សមត្ថកិច្ចដែលមានភារកិច្ចពន្យាពេលប័ណ្ណឆ្លងដែន ត្រូវចេញបង្កាន់ដៃទទួលពាក្យសុំ និងចុះហត្ថលេខាពន្យាពេលប័ណ្ណឆ្លងដែន ជូនប្រជាពលរដ្ឋក្នុងរយៈពេល០២ថ្ងៃយ៉ាងយូរ ចាប់ពីថ្ងៃទទួលពាក្យសុំ ។

**ប្រការ១០**: ប័ណ្ណឆ្លងដែន ដែលបានផ្តល់រួចហើយនឹងត្រូវបានដកហូត ឬបដិសេធ ក្នុងករណីដែលម្ចាស់ឯកសារនេះ :

ក_កំពុងត្រូវកាត់ទោស ឬ កំពុងជាប់ពន្ធនាគារ ឬ មានបទបញ្ជាតាមរកចាប់ខ្លួន ។

ខ_បានទទួលប័ណ្ណដោយសារការបំភ្លឺខុសពីការពិត ឬ ដោយការក្លែងបន្លំ ។

គ_កោសលប់ ឬ កែខ្លឹមសារ ឬ ដូររូបថត នៃប័ណ្ណឆ្លងដែន ។

**ប្រការ១១**: អគ្គលេខាធិការ អគ្គស្នងការនគរបាលជាតិ អគ្គនាយករដ្ឋបាល អគ្គាធិការកិច្ចការនគរបាលរដ្ឋបាល និងឯកឧត្តមអភិបាលខេត្ត ក្រុង ជាប់ព្រំដែនកម្ពុជា_ថៃ និងស្ថាប័នក្រោមឱវាទដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ភ្នំពេញ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០០៣*

**សមាជរដ្ឋមន្ត្រី**

ស ខេង

*កន្លែងទទួល* :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ដូចប្រការ ១១
- ឯកសារ_កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ : ០០៥ សរ

ភ្នំពេញ,ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០០៣

# សារាចរ

## ណែនាំអំពីការផ្តល់ “ ប័ណ្ណឆ្លងដែន ” ជូនប្រជាពលរដ្ឋខ្មែរ
## និងការគ្រប់គ្រងការឆ្លងកាត់ព្រំដែន

ដើម្បីអោយប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅក្នុងខេត្តជាប់ព្រំដែនជាមួយនឹងព្រះរាជាណាចក្រថៃ មានលិខិតស្នាមសំរាប់ប្រើប្រាស់ជាផ្លូវការ ក្នុងការធ្វើដំណើរឆ្លងកាត់ច្រកទ្វារព្រំដែនកម្ពុជា-ថៃ ក៏ដូចជាដើម្បីបង្កលក្ខណៈងាយស្រួលដល់អាជ្ញាធរមានសមត្ថកិច្ចគ្រប់គ្រងការចេញ-ចូលឆ្លងកាត់ព្រំដែន រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ បានព្រមព្រៀងគ្នាអោយបង្កើត **ប័ណ្ណឆ្លងដែន** សំរាប់ជូនប្រជាពលរដ្ឋប្រើប្រាស់ជាផ្លូវការចាប់ពីពេលនេះតទៅ ។

ក្រសួងមហាផ្ទៃសូមធ្វើការណែនាំដល់សមត្ថកិច្ចពាក់ព័ន្ធទាំងអស់ ត្រូវយកចិត្តទុកដាក់ស្វែងយល់ និងអនុវត្តការងាររបស់ខ្លួនអោយមានប្រសិទ្ធភាព និងលទ្ធផលល្អប្រសើរដូចខាងក្រោម ៖

**I-អំពីប័ណ្ណឆ្លងដែន :**

១-**ប័ណ្ណឆ្លងដែន** គឺជាឯកសារសំរាប់ធ្វើដំណើរមានកំណត់ពេល និងទីកន្លែងច្បាស់លាស់ ស្របតាមខ្លឹមសារអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៣ ស្តីពីការប្រើប្រាស់ប័ណ្ណឆ្លងដែនទៅតាមច្រកទ្វារព្រំដែនកម្ពុជា-ថៃ របស់រាជរដ្ឋាភិបាលកម្ពុជា ។

ក្នុងជំហានដំបូងនេះ ប្រជាពលរដ្ឋខ្មែរអាចប្រើប្រាស់ប័ណ្ណឆ្លងដែន ក្នុងការធ្វើដំណើរពីខេត្តបន្ទាយមានជ័យនៃព្រះរាជាណាចក្រកម្ពុជាឆ្លងចូលទៅខេត្តប្រាជីនបុរី ដោយឆ្លងកាត់ខេត្តស្រះកែវនៃព្រះរាជាណាចក្រថៃ ។ ការឆ្លងកាត់នេះត្រូវមានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ក្នុងគោលបំណងទៅសាកសួរសុខទុក្ខញាតិសន្តាន ពិនិត្យព្យាបាលជម្ងឺ ទេសចរណ៍ បំពេញភារកិច្ចផ្លូវការ ជំនួញ កីឡា ចូលរួមសិក្ខាសាលា កិច្ចប្រជុំ និងបំណងផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃបានព្រមព្រៀងគ្នា ។

២-អភិបាលខេត្តបន្ទាយមានជ័យ នៃព្រះរាជាណាចក្រកម្ពុជា លោកនាយប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ឬលោកនាយប៉ុស្តិ៍នគរបាលការពារព្រំដែនគោក ប្រចាំការនៅច្រកទ្វារព្រំដែនរបស់ខេត្តបន្ទាយមានជ័យ ជាមន្ត្រីមានសមត្ថកិច្ចក្នុងការផ្តល់ប័ណ្ណឆ្លងដែន ។

៣-ប័ណ្ណឆ្លងដែនមាន ០២ប្រភេទ គឺប័ណ្ណឆ្លងដែនពណ៌ខៀវ និងប័ណ្ណឆ្លងដែនពណ៌លឿងៈ

-អភិបាលខេត្តបន្ទាយមានជ័យមានសិទ្ធិចេញប័ណ្ណឆ្លងដែនពណ៌ខៀវ ជូនប្រជាពលរដ្ឋដែលរស់នៅក្នុងខេត្តបន្ទាយមានជ័យ ។

-លោកនាយប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ឬលោកនាយប៉ុស្តិ៍នគរបាលការពារព្រំដែនគោក ប្រចាំនៅច្រកទ្វារព្រំដែនរបស់ខេត្តបន្ទាយមានជ័យ មានសិទ្ធិចេញប័ណ្ណពណ៌លឿងជូនប្រជាពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តបន្ទាយមានជ័យ ។

៤-ក្រសួងមហាផ្ទៃជាអ្នកផ្គត់ផ្គង់ និងផ្តល់ប័ណ្ណឆ្លងដែនទាំង ០២ប្រភេទនេះ ជូនទៅខេត្តបន្ទាយមានជ័យ និងមានវិធានការបង្ការការផលិត និងប្រើប្រាស់ប័ណ្ណឆ្លងដែនក្លែងក្លាយ ។ល។

ប័ណ្ណឆ្លងដែននីមួយៗ មានលក្ខណៈសំគាល់ដូចខាងក្រោម ៖

ក-នៅក្របខាងក្រៅមាន :

-រូបព្រះរាជសង្ហារពណ៌មាស និងរូបសញ្ញាក្រសួងមហាផ្ទៃពណ៌លឿង

-ក្រោមព្រះរាជសង្ហារមានសរសេរអក្សរខ្មែរថា "ព្រះរាជាណាចក្រកម្ពុជា "

-ក្រោមអក្សរខ្មែរមានអក្សរអង់គ្លេសថា " KINGDOM OF CAMBODIA "

-ក្រោមអក្សរអង់គ្លេសនៅចំកណ្តាលរូបសញ្ញាក្រសួងមហាផ្ទៃ មានសរសេរអក្សរខ្មែរថា " ប័ណ្ណឆ្លងដែន "

-ក្រោមអក្សរខ្មែរមានអក្សរអង់គ្លេសថា " **Border Pass** "

-ក្រោមអក្សរអង់គ្លេសមានសរសេរថា លេខ:................

ខ-នៅខាងក្នុងប័ណ្ណឆ្លងដែនមានកំណត់អំពីលក្ខណៈសំគាល់របស់អ្នកកាន់ប័ណ្ណឆ្លងដែនម្នាក់ៗដូចតទៅៈ

-នាមត្រកូលៈ................................

-នាមខ្លួនៈ...................................

-ថ្ងៃខែឆ្នាំកំណើតៈ.......................... ភេទៈ..........

-ទីកន្លែងកំណើតៈ..........................

-មុខរបរៈ...................................

-អត្តសញ្ញាណប័ណ្ណលេខៈ..................

-មានស្នាមពិសេសៈ ........................

-អាស័យដ្ឋានៈ...............................

-កន្លែងមិនរូបថត:

-ហត្ថលេខា ឬស្នាមផ្តិតមេដៃស្តាំ:......................

-ធ្វើនៅ............... ផ្តល់នៅថ្ងៃទី .................

-ផុតកំណត់ថ្ងៃទី......................................

-ហត្ថលេខា និងត្រាមន្ត្រីអន្តោប្រវេសន៍:...............

ចំពោះប័ណ្ណឆ្លងដែនដែលបញ្ចូលឈ្មោះកូនស្របច្បាប់របស់អ្នកកាន់ប័ណ្ណឆ្លងដែន (អាយុក្រោម ១២ឆ្នាំ) ត្រូវមានកំណត់លក្ខណៈសំគាល់របស់កូនស្របច្បាប់ទាំងនោះដូចតទៅ :

-នាមត្រកូល និងនាមខ្លួន:................

-ភេទ:............

-ថ្ងៃ ខែ ឆ្នាំកំណើត:......................

-ទីកន្លែងកំណើត:........................

-កន្លែងមិនរូបថត:

លក្ខណៈសំគាល់ផ្សេងៗដូចបានរៀបរាប់ខាងលើ ត្រូវសរសេរបំពេញក្នុងប័ណ្ណឆ្លងដែនជាអក្សរខ្មែរ និងអង់គ្លេស ។ អក្សរបំពេញលក្ខណៈសំគាល់ចុះក្នុងប័ណ្ណឆ្លងដែន ត្រូវសរសេរអោយបានច្បាស់ មិនត្រូវកោសលុប ឬសរសេរជ្រៀតថែមឡើយ ។

៥-ប័ណ្ណឆ្លងដែនមានសុពលភាពសំរាប់រយៈពេល ០២ឆ្នាំ គិតចាប់ពីថ្ងៃចេញប័ណ្ណ ។ ផុតកំណត់រយៈពេលប្រើប្រាស់ អ្នកកាន់ប័ណ្ណឆ្លងដែនត្រូវស្នើសុំប័ណ្ណថ្មី ។

II-<u>**អំពីនីតិវិធីនៃការផ្តល់ និងការប្រើប្រាស់ប័ណ្ណឆ្លងដែន**</u> **:**

១-ជំហានដំបូងនេះ ប័ណ្ណឆ្លងដែនត្រូវបានផ្តល់ជូនចំពោះតែប្រជាពលរដ្ឋខ្មែរ ដែលមានអាយុចាប់ពី ១២ឆ្នាំឡើង ហើយជាអ្នកស្នាក់នៅអចិន្ត្រៃយ៍ក្នុងខេត្តបន្ទាយមានជ័យនៃព្រះរាជាណាចក្រកម្ពុជា ។

២-អ្នកស្នើសុំប័ណ្ណឆ្លងដែនជាពលរដ្ឋខ្មែរ ដែលត្រូវជាឪពុក ឬម្តាយ អាចសុំបំពេញបែបបទសំរាប់បញ្ចូលក្នុងប័ណ្ណឆ្លងដែនរបស់ខ្លួនទនូវកូនស្របច្បាប់ អាយុក្រោម ១២ឆ្នាំ ដែលត្រូវរួមដំណើរជាមួយ ។

៣-ប័ណ្ណឆ្លងដែននឹងមិនត្រូវផ្តល់ជូនចំពោះជនប្រព្រឹត្តបទល្មើសអំពីគ្រឿងញៀន វត្ថុបុរាណ ការជួញដូរមនុស្ស ជនវិកលចរិក ជនដែលកំពុងស្ថិតនៅក្នុងស្ថានភាពជាទណ្ឌិត និងពិរុទ្ធជន ។

៤-អ្នកស្នើសុំប័ណ្ណឆ្លងដែនអាចដាក់ពាក្យស្នើសុំនៅសាលាខេត្តបន្ទាយមានជ័យ ឬនៅប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ឬនៅប៉ុស្តិ៍នគរបាលការពារព្រំដែនគោកប្រចាំច្រកទ្វារព្រំដែន ដែលស្ថិតនៅក្នុងខេត្តបន្ទាយមានជ័យ តាមរយៈមេឃុំ លោកអភិបាលស្រុក នៃទីកន្លែងដែលសាមីខ្លួនស្នាក់នៅអចិន្ត្រៃយ៍ ដោយភ្ជាប់មកជាមួយនូវ : <

-ពាក្យស្នើសុំដែលមានការបញ្ជាក់ទទួលស្គាល់ពីមេឃុំ និងអភិបាលស្រុក ០១ច្បាប់ ដោយមិនតែមប្រ៊ី ។

-ជីវប្រវត្តិសង្ខេប ចំនួន ០១ច្បាប់

-លិខិតបញ្ជាក់ទីលំនៅដែលចេញដោយមេឃុំ ឬច្បាប់ចំលងអត្តសញ្ញាណប័ណ្ណ ឬសេចក្តីចំលងសំបុត្រកំណើត ០១ច្បាប់ ។

-រូបថត ៤ × ៦ ចំនួន ០៣សន្លឹក (ថតចំពីមុខគ្មានពាក់មួក និងវ៉ែនតាពណ៌ខ្មៅ)

-លិខិតអនុញ្ញាតពីឪពុកម្តាយ ឬអាណាព្យាបាល ប្រសិនបើជាអនីតិជន ។

-អ្នកស្នើសុំប័ណ្ណឆ្លងដែនមានភារកិច្ចបង់ថ្លៃប័ណ្ណឆ្លងដែន និងថ្លៃលិខិតស្នាមផ្សេងៗ សំរាប់បំរើការផ្តល់ប័ណ្ណឆ្លងដែនជូនអាជ្ញាធរមានសមត្ថកិច្ច ដែលផ្តល់ប័ណ្ណឆ្លងដែនប្រភេទនីមួយៗ ស្មើនឹងទឹកប្រាក់ចំនួន ២០.០០០ រៀល (ម្ភៃពាន់រៀល) ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវចេញបង្កាន់ដៃទទួលប្រាក់ជូនប្រជាពលរដ្ឋដែលបានបង់ថ្លៃរួច ហើយត្រូវចុះបញ្ជីគ្រប់គ្រងដោយឡែក និងរក្សាទុកគល់បញ្ជីបង្កាន់ដៃទទួលប្រាក់អោយបានត្រឹមត្រូវ និងគង់វង្ស ។

៦-អ្នកកាន់ប័ណ្ណឆ្លងដែនដែលចេញដោយអភិបាលខេត្តបន្ទាយមានជ័យ ឬដោយនាយប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ឬដោយនាយប៉ុស្តិ៍នគរបាលព្រំដែនគោក ប្រចាំច្រកទ្វារព្រំដែន អាចធ្វើដំណើរចូលទៅខេត្តប្រាជីនបុរីរបស់ព្រះរាជាណាចក្រថៃបាន ដោយឆ្លងកាត់តាមខេត្តស្រះកែវ ។

ក្នុងការធ្វើដំណើរចូល និងស្នាក់នៅក្នុងខេត្តស្រះកែវ ឬខេត្តប្រាជីនបុរីនៃព្រះរាជាណាចក្រថៃម្តងៗ អ្នកកាន់ប័ណ្ណអាចស្នាក់នៅបានរយៈពេល ០៧ថ្ងៃ ។ ចំពោះការស្នាក់នៅដែលមានរយៈពេលលើសពីនេះ តែមិនហួសពី ១៥ថ្ងៃ ត្រូវសុំការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចនៃខេត្តដែលសាម៉ីជនស្នាក់នៅ ។

៧-ចំពោះប្រជាពលរដ្ឋថៃអាចធ្វើដំណើរចេញពីខេត្តស្រះកែវ មកខេត្តសៀមរាបដោយឆ្លងកាត់ខេត្តបន្ទាយមានជ័យ ។ ក្នុងការធ្វើដំណើរចូល និងស្នាក់នៅក្នុងខេត្តបន្ទាយមានជ័យ ឬខេត្តសៀមរាបនៃព្រះរាជាណាចក្រកម្ពុជា អ្នកកាន់ប័ណ្ណអាចស្នាក់នៅបានរយៈពេល ០៧ថ្ងៃ ។ ចំពោះការស្នាក់នៅដែលមានរយៈពេលលើសពីនេះ តែមិនហួសពី ១៥ថ្ងៃ ត្រូវសុំការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចនៃខេត្តដែលសាម៉ីខ្លួនស្នាក់នៅ ។

៨-នៅពេលធ្វើដំណើរចេញ-ចូលខេត្តជាប់ព្រំដែន តាមច្រកដែលអនុញ្ញាតអោយចេញ-ចូល អ្នកកាន់ប័ណ្ណឆ្លងដែនត្រូវបង្ហាញប័ណ្ណរបស់ខ្លួនជូនមន្ត្រីអន្តោប្រវេសន៍ ដែលកំពុងបំពេញភារកិច្ចនៅច្រកដែលខ្លួនចេញចូល ដើម្បីចុះបញ្ជី និងបោះត្រាអនុញ្ញាត ។

៩-អ្នកកាន់ប័ណ្ណឆ្លងដែនត្រូវរក្សាប័ណ្ណរបស់ខ្លួនអោយបានគង់វង្ស មិនត្រូវអោយអ្នកដ៏ទៃខ្ចីយកទៅប្រើ កោសលុបសរសេរថែម ឬធ្វើអោយខូចទ្រង់ទ្រាយដើមនៃប័ណ្ណឆ្លងដែនរបស់ខ្លួនឡើយ ។

នៅពេលមានការខូចខាត ឬបាត់បង់ប័ណ្ណឆ្លងដែនដោយប្រការណាមួយ អ្នកកាន់ប័ណ្ណឆ្លងដែនត្រូវរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរមានសមត្ថកិច្ច ដែលចេញប័ណ្ណនោះ ។

ជនណាក្លែងបន្លំប័ណ្ណឆ្លងដែននឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

១០-នៅពេលឆ្លងចូលទៅខេត្តជាប់ព្រំដែនដែលបានអនុញ្ញាត អ្នកកាន់ប័ណ្ណឆ្លងដែនត្រូវគោរពច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅទីនោះ ។

អ្នកកាន់ប័ណ្ណឆ្លងដែនដែលធ្វើដំណើរហួសពីតំបន់ដែលបានកំណត់ នឹងត្រូវទទួលរងការផ្តន្ទាទោសតាមច្បាប់អន្តោប្រវេសន្ត និងបទប្បញ្ញត្តិជាធរមាននៅប្រទេសដែលខ្លួនឆ្លងចូលទៅនោះ ។

**III-<u>អំពីការគ្រប់គ្រងការឆ្លងកាត់ព្រំដែន</u> :**

១-ចាប់ពីពេលនេះទៅ អភិបាលខេត្ត ក្រុង លោកនាយប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិនានា ឬលោកនាយប៉ុស្តិ៍នគរបាលការពារព្រំដែនគោកប្រចាំការនៅច្រកទ្វារព្រំដែនរបស់ខេត្ត ក្រុងនីមួយៗ ដែលនៅជាប់ព្រំប្រទល់ជាមួយព្រះរាជាណាចក្រថៃ ត្រូវផ្អែកតាមស្មារតីនៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការឆ្លងកាត់ព្រំដែនរវាងប្រទេសទាំង២ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ និងកិច្ចព្រមព្រៀងអង្គប្រជុំគណៈរដ្ឋមន្ត្រីចំរុះកម្ពុជា-ថៃ នាថ្ងៃទី៣១ ខែឧសភា និងថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៣ ដើម្បីពិនិត្យវាយតំលៃសភាពការណ៍សន្តិសុខជាក់ស្តែងនៅតំបន់ព្រំដែន រួចធ្វើសេចក្តីរាយការណ៍បញ្ជាក់អំពីស្ថានភាពជាក់ស្តែងនៃច្រកទ្វាព្រំដែននីមួយៗ តើច្រកទ្វារព្រំដែនណា ដែលអាចបើកដំណើរការបាន និងមិនទាន់អាចដំណើរការបាន ផ្ញើតាមឋានានុក្រមមកក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងសំរេចអនុញ្ញាតអោយដំណើរការ ។

២-ចំពោះច្រកទ្វារព្រំដែនដែលត្រូវអនុញ្ញាតអោយដំណើរការបាន ក្នុងពេលដំណើរការ អភិបាលខេត្ត ក្រុងពាក់ព័ន្ធ អគ្គស្នងការដ្ឋាននគរបាលជាតិ និងនាយកដ្ឋានជំនាញ ត្រូវណែនាំដល់គ្រប់ភ្នាក់ងារមានសមត្ថកិច្ចអោយគ្រប់គ្រងការចេញ-ចូលឆ្លងកាត់ព្រំដែនរបស់ប្រជាពលរដ្ឋខ្មែរ និងជនបរទេសអោយបានត្រឹមត្រូវ ខិតខំការពារសន្តិសុខ រក្សាសណ្តាប់ធ្នាប់សាធារណៈតាមច្រកទ្វារព្រំដែននីមួយៗ និងទប់ស្កាត់អោយបានដាច់ខាតការឆ្លងកាត់ព្រំដែនដោយខុសច្បាប់ ។

៣-អគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវណែនាំដល់កងកំលាំងនគរបាលអន្តោប្រវេសន្ត និងកងកំលាំងនគរបាលការពារព្រំដែនគោក ដែលបានចាត់អោយប្រចាំការនៅតាមច្រកទ្វារដែលត្រូវបានអនុញ្ញាតអោយដំណើការត្រូវមានអាកប្បកិរិយាទន់ភ្លន់ រួសរាយរាក់ទាក់ ប៉ុន្តែត្រូវម៉ឺងម៉ាត់ក្នុងការងារ ។ ត្រូវណែនាំអំពីនីតិវិធីនៃការផ្តល់ និងការប្រើប្រាស់ប័ណ្ណឆ្លងដែន ជៀសវាងការផ្តល់ប័ណ្ណទៅអោយមុខសញ្ញាណាដែលមិនត្រូវផ្តល់ ។ ត្រូវណែនាំអំពីរបៀបរបបចាត់ចែងរៀបរយប្រជាពលរដ្ឋខ្មែរ និងបរទេស ដែលមានប័ណ្ណឆ្លងដែនស្របច្បាប់ចេញ-ចូល ឆ្លងកាត់តាមច្រកទ្វារដែលបានអនុញ្ញាត អោយមានសណ្តាប់ធ្នាប់ល្អ ។ ត្រូវណែនាំអោយមានសៀវភៅចុះលេខតាមដានការចេញ-ចូល ឆ្លងកាត់ព្រំដែនរបស់ប្រជាពលរដ្ឋខ្មែរ និងបរទេសអោយបានទៀងទាត់ ។ នៅរៀងរាល់ចុងសប្តាហ៍នីមួយៗ ត្រូវធ្វើសេចក្តីរាយការណ៍ជូនអភិបាលខេត្ត ក្រុង ដែលច្រកទ្វារនោះតាំងនៅ អំពីចំនួនប្រជាពលរដ្ឋខ្មែរ និងបរទេស ដែលបានអនុញ្ញាតអោយចេញ-ចូលឆ្លងកាត់ច្រកទ្វារព្រំដែន ចំនួនអ្នករិលត្រឡប់

ចេញ-ចូលបានត្រឹមត្រូវ តាមកាលបរិច្ឆេទដែលអនុញ្ញាត ចំនួននិងឈ្មោះអ្នកដែលមិនឃើញវិលត្រឡប់ចេញ និងចូលមកវិញ ។

នៅរៀងរាល់ចុងខែនីមួយៗ អភិបាលខេត្ត ក្រុងត្រូវសរុបរាយការណ៍មកក្រសួងមហាផ្ទៃ ដើម្បីជាពត៌មានផង ។ ចំពោះអ្នកដែលមិនឃើញវិលត្រឡប់ចេញ-ចូលមកវិញ អភិបាលខេត្ត ក្រុង ត្រូវចាត់ចែងស្រាវជ្រាវរកជាបន្ទាន់ដើម្បីមានវិធានការទាន់ពេលវេលា ។

ទទួលបានសារាចរនេះ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានរដ្ឋបាល សាលាខេត្ត-ក្រុងនៅតាមព្រំដែនកម្ពុជា-ថៃ ត្រូវធ្វើការផ្សព្វផ្សាយអោយបានទូលំទូលាយដល់គ្រប់ភ្នាក់ងារមានសមត្ថកិច្ចពាក់ព័ន្ធ និងអាជ្ញាធរដែនដីក្រោមឱវាទ ជាមួយនោះក៏ត្រូវធ្វើការផ្សព្វផ្សាយស្មារតីនៃសារាចរ និងកិច្ចព្រមព្រៀងកម្ពុជា-ថៃ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ និងស្មារតីនៃកិច្ចប្រជុំគណៈរដ្ឋមន្ត្រីចំរុះកម្ពុជា-ថៃ ចុះថ្ងៃទី៣១ ខែឧសភា និងថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៣ ជូនដល់ប្រជាពលរដ្ឋនៃខេត្តជាប់ព្រំដែនថៃ និងខេត្តសៀមរាប អោយបានយល់ជ្រួតជ្រាប និងអនុវត្តត្រឹមត្រូវគ្រប់ៗគ្នា ។

ស ខេង

*__ចំលងជូន__ :*

*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង*
*-គ្រប់ក្រសួង ស្ថាប័ន*
*"ដើម្បីជូនជ្រាប"*
*-គ្រប់អង្គភាពចំណុះក្រសួងមហាផ្ទៃ*
*"ដើម្បីអនុវត្ត"*
*-ឯកសារ*